មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0077**

# សម្ភាសន៍ជាមួយឈ្មោះ ស៊ឹម រីម ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងាររជនាន់ខ្មែរក្រហម«យោធា»

## រស់នៅភូមិអូរតេរី ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

## ថ្ងៃទី១៩ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០១:០១:២០

២៨ទំព័រ

វណ្ណៈ: ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

រីមៈ ខ្ញុំបាទ ឈ្មោះ ស៊ឹម រីម ។

វណ្ណៈ: អាយុប៉ុន្មានហើយពូ?

រីមៈ អាយុ៥៨ ។

វណ្ណៈ: ចឹងប្រពន្ធពូឈ្មោះអីដែរ?

រីមៈ ឈ្មោះ គឹម វ៉េត ។

វណ្ណៈ: ចឹងឈ្មោះគឹម វ៉េត?

រីមៈ បាទ ។

វណ្ណៈ: គាត់អាយុប៉ុន្មានដែរ?

រីមៈ អាយុ៥១ ។

វណ្ណៈ: ចឹងអាយុ៥១?

រីមៈ បាទ ។

វណ្ណៈ: ពូមានកូនប៉ុន្មាននាក់?

រីមៈ ខ្ញុំមានកូន៦នាក់ ។

វណ្ណៈ: ចឹងមានស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

រីមៈ ស្រី១ ។

វណ្ណៈ: ចឹងស្រី១?

រីមៈ បាទ! ប្រុសមាន៥ ។

វណ្ណៈ: ចឹងសព្វថ្ងៃកូនមានបានរៀបការខ្លះហើយនៅ?

រីមៈ		រៀនការមួយបានកូនពីរ ។

វណ្ណៈៈ		ចឹងមានកូនការមួយហើយ?

រីមៈ		បាទ!ការកូនស្រីកូនច្បង ។

វណ្ណៈៈ		ចឹងឪពុកពូឈ្មោះអីដែរ?

រីមៈ		ឪពុកខ្ញុំឈ្មោះសុនហ្នឹងហើយ ។

វណ្ណៈៈ		ចឹងត្រកូលគាត់ស្គាល់ទេ?

រីមៈ		ត្រកូលគាត់អត់ស្គាល់ដែរ ។

វណ្ណៈៈ		ចឹងម្ដាយ?

រីមៈ		ម្ដាយឈ្មោះ តេង ។

វណ្ណៈៈ		ចឹងត្រកូលគាត់?

រីមៈ		ត្រកូលគាត់មិនដឹងជាឈ្មោះអីអត់ស្គាល់ដែរ?

វណ្ណៈៈ		ចឹងរាល់ថ្ងៃហ្នឹងគាត់នៅរស់ដែរ?

រីមៈ		គាត់ខូចហើយ ។

វណ្ណៈៈ		គាត់ស្លាប់សម័យណា?

រីមៈ		គាត់ទើបស្លាប់កាលឆ្នាំទៅមួយទេ ។

វណ្ណៈៈ		ចឹងគាត់ស្លាប់ក្រោយ៧៩?

រីមៈ		បាទ ។

វណ្ណៈៈ		គាត់ស្លាប់ដោយចាស់ជរា ឪពុកគាត់ស្លាប់មុន?

រីមៈ		ឪពុកស្លាប់កាលពីឆ្នាំ៧៨ខ្ញុំមិនបាននៅទេ?

វណ្ណៈៈ		ចឹងស្លាប់ឆ្នាំ៧៨ជំនាន់ខ្មែរក្រហម?

រីមៈ		បាទ!ជំនាន់ខ្មែរក្រហមហ្នឹង ។

វណ្ណៈៈ		ចឹងម្ដាយស្លាប់ឆ្នាំ១៩៨០អះ!ឆ្នាំ២០០០?

រីមៈ		គាត់ស្លាប់ឆ្នាំ២០០៩ ។

វណ្ណៈៈ		ចឹងម្ដាយស្លាប់ឆ្នាំ២០០៩ឪពុកម្ដាយឆ្នាំ១៩៧៨ជំនាន់ខ្មែរក្រហម?

រីមៈ		បាទ ។

វណ្ណៈៈ		ចឹងពូមានដឹងថាគាត់ស្លាប់ដោយសារអីទេ?

រីមៈ		ខ្ញុំមិនបានដឹងដែលព្រោះខ្ញុំចេញមកតស៊ូបាត់ទៅ ។

វណ្ណៈ ចឹងពូចេញតស៊ូ?

រីមៈ បាទ ។

វណ្ណៈ ចឹងកាលពីតូចពីរៀនបានត្រឹមណា?

រីមៈ ជំនាន់ហ្នឹងខ្ញុំរៀនបានថ្នាក់ប្រេយាងអងថ្នាក់ទី៩ យើងពីសង្គមនោះ ។

វណ្ណៈ ចឹងរៀនត្រឹមថ្នាក់ទី៩ «ចាស់» ?

រីមៈ បាទ ។

វណ្ណៈ ចឹងចេះអានចេះសរសេរពូ?

រីមៈ បាទ ។

វណ្ណៈ ចឹងពូឈប់រៀននៅឆ្នាំណា?

រីមៈ ឈប់ឆ្នាំគេធ្វើរដ្ឋប្រហារហ្នឹង ។

វណ្ណៈ ឆ្នាំ១៩៧០ ?

រីមៈ បាទ ។

វណ្ណៈ ឈប់រៀនពូធ្វើអីវិញ?

រីមៈ ឈប់រៀនកាលហ្នឹងគេធ្វើរដ្ឋប្រហារហើយ ក្រោយមកចូលទ័ព ។

វណ្ណៈ ចូលនៅឆ្នាំណា?

រីមៈ ចូលនៅឆ្នាំ៧២ ។

វណ្ណៈ ចូលដំបូងពូចូលនៅកន្លែងណាទៅ?

រីមៈ ចូលដំបូងធ្វើឈ្លបឃុំ រួចមកបានគេបញ្ជូនទៅទ័ព ។

វណ្ណៈ ចឹងឈ្លបឃុំ?

រីមៈ បាទ!កាលពីដើមចូលឈ្លបឃុំដល់ហើយ ។

វណ្ណៈ ឃុំអីគេ?

រីមៈ ឃុំចារ ។

វណ្ណៈ ឃុំចារ?

រីមៈ បាទ!ស្រុកព្រៃកប្បាស ។

វណ្ណៈ ចឹងស្រុកព្រៃកប្បាស?

រីមៈ បាទ!ខេត្តតាកែវ ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងភូមិកំណើតពូនៅភូមិអី?

រឹមៈ នៅភូមិស្វាយចាស់ ឃុំចារ ។

វណ្ណៈ ស្រុកព្រៃកប្បាសចឹងពូ?

រឹមៈ បាទ ។

វណ្ណៈ ខេត្តតាកែវ?

រឹមៈ បាទ!ខេត្តតាកែវ ។

វណ្ណៈ ចុះឥឡូវពូនៅភូមិអីវិញ?

រឹមៈ ឥឡូវនេះនៅក្នុងភូមិអូរគគីរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

វណ្ណៈ ខេត្តបាត់ដំបង?

រឹមៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងចូលនៅឆ្នាំ១៩៧២ កាលហ្នឹងពូចូលដោយស្មគ្រ័ចិត្តឬមួយបង្ខំឲ្យចូល?

រឹមៈ កាលជំនាន់ហ្នឹងមិនបង្ខំទេ តែដូចជាបង្ខំដែលជំនាន់ហ្នឹងគ្មានពីណានៅបាន ។

វណ្ណៈ សម័យសង្រ្គាមពីយល់ឃើញយ៉ាងម៉េចបានពូចូល?

រឹមៈ កាលហ្នឹងបើនិយាយទៅដូចជាបង្ខំដែរ កាលហ្នឹងគេទៅទូទាំងភូមិទូទាំងឃុំហើយណា ។

វណ្ណៈ បាទ ។

រឹមៈ ដល់ចឹងហើយយើងមិនអាចនៅបាន គេឲ្យទៅចេះតែទៅៗ ។

វណ្ណៈ ចឹងនៅក្នុងភូមិចារធ្វើឈ្លបនិងរយៈពេលប៉ុន្មានបានពូទៅស្រុកវិញ ទៅចូលកងទ័ពតែម្តង?

រឹមៈ នៅប្រហែលជាមួយឆ្នាំ ។

វណ្ណៈ ចឹងមើល៧២ហ្នឹងនៅឈ្លប៧៣ហ្នឹងមានការទម្លាក់គ្រាប់បែកអាមេរិចកាំង?

រឹមៈ បាទ ។

វណ្ណៈ ចឹងពូបានធ្វើហើយ?

រឹមៈ បាទ ។

វណ្ណៈ ចឹងនៅពេល៧៥ដែលខ្មែរក្រហមរំដោះបានខ្មែរក្រហមឈ្នះនៅឆ្នាំ១៩៧៥ចូលភ្នំពេញបាន ពូមានចូលដែរ?

រឹមៈ ខ្ញុំចូលមកដែលឆ្លងកាត់ភ្នំពេញបានមួយយប់ដល់ពេលចឹងគេបញ្ជូនទៅខាងក្រចេះហ្នឹងនៅ ក្រចេះបានបីខែបានគេបញ្ជូនទៅមណ្ឌលគិរីតែម្តង ។

វណ្ណៈ អូរចឹង!ឆ្នាំ១៩៧៥ចូលដល់ភ្នំពេញ?

រឹមៈ បាទ ។

វណ្ណៈ៖ ចឹងនៅភ្នំពេញបានមួយខែទេ?

រីមៈ អត់ទេ សម្រាកហ្នឹងបានតែមួយយប់ ព្រោះមុនសញ្ញាពួកខ្ញុំមិនបាននៅហ្នឹងគេបញ្ជូនបង្ហួសទៅ ។

វណ្ណៈ៖ ចឹងមួយយប់ទៅក្រចេះ?

រីមៈ បាទ ។

វណ្ណៈ៖ ចឹងកាលមុនចូលវ៉ៃចូលទីក្រុងភ្នំពេញពូនៅកងពលណា?

រីមៈ នៅកងពលទី៣ កាលជំនាន់ហ្នឹង ។

វណ្ណៈ៖ ចឹងកងពលទី៣ពីណាជាអ្នកដឹកនាំ?

រីមៈ ឈ្មោះ ម៉ែគាត់ជាប្រធានកងពល ។

វណ្ណៈ៖ ចឹងមិនមែនតា ណាតទេ?

រីមៈ បាទ!មិនមែនទេ តា ណាគាត់ខាងភូមិភាគពិសេសពួកខ្ញុំខាងភូមិភាគនិរតី ។

វណ្ណៈ៖ ពូនៅជាមួយតា ម៉ែរហូតឬមួយយ៉ាងម៉េច?

រីមៈ កាលហ្នឹងនៅមិនបានជាប់ទេ ដល់ក្រោយមកបែកគ្នា ដល់ក្រោយកន្លងទៅទៀតហ្នឹងអត់ដឹងទេ ។

វណ្ណៈ៖ ចឹងពូចេញទៅនៅក្រចេះចេញពីតា ម៉ែហើយហ្នឹង?

រីមៈ បាទ ។

វណ្ណៈ៖ ទៅនៅក្រចេះហ្នឹងនៅក្នុងខេត្តក្រចេះហ្នឹងតែម្ដងឬមួយយ៉ាងម៉េច?

រីមៈ នៅទីក្រុងនិងតែម្ដងនៅរយៈបានបីខែ ។

វណ្ណៈ៖ ចឹងឆ្នាំ៧៥ នៅក្រចេះបានបីខែ?

រីមៈ បាទ!បីខែនៅក្រចេះខែ១០ឆ្នាំ៧៦ បានគេបញ្ជូនឡើងទៅមណ្ឌលគិរី ។

វណ្ណៈ៖ ចឹងឆ្នាំ១៩៧៦ ទៅមណ្ឌលគិរីឬរតនៈគិរី?

រីមៈ ទៅមណ្ឌលគិរី ។

វណ្ណៈ៖ ចឹងនៅមណ្ឌលគិរីនៅហ្នឹងរហូតដល់ឆ្នាំ៧៩?

រីមៈ បាទ!រហូតដល់ឆ្នាំ៨២ ប៉ុនកាលហ្នឹងវៀតណាមចូលមករំដោះហ្នឹងកាលឆ្នាំ៧៩កាលហ្នឹង ។

វណ្ណៈ៖ បាទ ។

រីមៈ ដល់ចឹងពួកខ្ញុំនៅព្រៃរហូតដល់ឆ្នាំ៨២ បានឡើងមកដល់ភ្នំដងរែក ។

វណ្ណៈ៖ ចឹងកាលពូទៅនៅមណ្ឌលគិរីមានពីណាគ្រប់គ្រងវិញ?

រីមៈ	កាលពីដើមហ្នឹងខ្ញុំនៅកងពល៩២០ ។

វណ្ណៈ	មណ្ឌលគិរីកងពល៩២០ហ្នឹងពីណាជាប្រធានកងពល?

រីមៈ	កាលហ្នឹងឈ្មោះឈិន ក្រោយមកគេចាប់គាត់ដូចថាគាត់ហ្នឹងចូលទៅខាងវៀតណាមអីចឹង ។

វណ្ណៈ	បាទ ។

រីមៈ	ដល់ចឹងគេថាគាត់ក្បត់ក៏គេចាប់គាត់ ។

វណ្ណៈ	ដល់ក្រោយមកពីណាចូលវិញ?

រីមៈ	ដល់ក្រោយមកបានគេបញ្ជូនពួកខ្ញុំប្រហែលជាបីពាន់នាក់ហ្នឹង គេបញ្ជូនមកខាងខេត្តខាងតំបន់មណ្ឌលគិរីហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងទាហានបីពាន់នាក់?

រីមៈ	កាលហ្នឹងកងទ័ពទាំងស្រីទាំងប្រុសចំនួនប្រហែលជាបីពាន់នាក់ ។

វណ្ណៈ	ខេត្តមណ្ឌលគិរី?

រីមៈ	បាទ! គេបញ្ជូនមកខេត្តមកនៅក្នុងខេត្តវិញ ។

វណ្ណៈ	ចឹងដែលនៅការពារព្រំដែនហើយ?

រីមៈ	កន្លែងហ្នឹងព្រំដែនខាងកើតហើយមណ្ឌលគិរី ។

វណ្ណៈ	ចឹងនៅពេលចាប់តា ឈិនទៅហ្នឹងពីណាមកធ្វើប្រធានកងពលវិញ?

រីមៈ	ក្រោយមកខាងកងពលនេះ ព្រោះខ្ញុំមកខាងតំបន់ហើយដល់កងពលក្រោយមកឈ្មោះ សាន ។

វណ្ណៈ	ចឹងឈ្មោះ សាន?

រីមៈ	បាទ ។

វណ្ណៈ	ឡើងប្រធានកងពល?

រីមៈ	បាទ ។

វណ្ណៈ	ដល់ក្រោយមកបន្ទាប់ពីសាន?

រីមៈ	ដល់ក្រោយមកខ្ញុំលែងដឹងហើយ ។

វណ្ណៈ	ពូលែងដឹងពូមកនៅណាវិញមកតំបន់?

រីមៈ	ដល់ហើយគេបញ្ជូនមកខាងតំបន់អស់ទៅ ។

វណ្ណៈ	តំបន់ប៉ុន្មាន?

រីមៈ	តំបន់ខេត្តមណ្ឌលគិរីហ្នឹង កាលហ្នឹងគេមិនមែនហៅខេត្តទេ គេហៅតំបន់ ។

វណ្ណៈ៖ ចឹងតំបន់ប៉ុន្មានពូមានដឹងទេ?

រីមៈ តំបន់មណ្ឌលគិរីមិនដឹងជាលេខប៉ុន្មាន តំបន់គេកែប្រែខ្ញុំអត់ដឹងដែរ ។

វណ្ណៈ៖ ប្រធានតំបន់ពីណាគេ?

រីមៈ ឈ្មោះហមតែគាត់ស្លាប់ហើយ ។

វណ្ណៈ៖ ចឹងកាលពូនៅមណ្ឌលគិរីហ្នឹងតើគេការពារអីខ្លះទៅ?

រីមៈ ជំនាន់ហ្នឹងមានខាងកងស្រួចមានខាងកងចល័តចឹងទៅ ហើយមានកងទ័ពការពារខាងព្រំដែនក៏មាន ។

វណ្ណៈ៖ ការពារហ្នឹងការពារកុំឲ្យប្រជាជនរត់ទៅស្រុកគេឬមួយការពារយ៉ាងម៉េច?

រីមៈ ការពារខាងព្រំដែនចឹងឧទាហរណ៍មិនឲ្យប្រទេសក្រៅចូលមកទឹកដីយើង ដូចយើងនៅការពារសៀមចឹង ។

វណ្ណៈ៖ បាទ ។

រីមៈ ការពារនៅខាងនោះការពារវៀតណាម ។

វណ្ណៈ៖ ខ្លាចរំលោភយកដីអីហ្នឹង?

រីមៈ បាទ!ជំនាន់ហ្នឹងគេឲ្យនៅការពារ ការពារចឹង ។

វណ្ណៈ៖ ចឹងការពារជាយោធាចឹងការហូបចុកយ៉ាងម៉េចដែលពេលហ្នឹង?

រីមៈ និយាយទៅជំនាន់ហ្នឹងនិយាយទៅដូចជាតាមតំបន់ដែលទេ បើតំបន់ណាគេអត់មានខ្វះខាតចឹងទៅក៏គេហូបចុកបបូរទៅ តំបន់ណាខ្វះខាតទៅហូបបបរហូបអីទៅ ។

វណ្ណៈ៖ បាទ ។

រីមៈ តែកាលជំនាន់ហ្នឹងគេហៅថាសម័យកសាងនោះ ។

វណ្ណៈ៖ បាទ ។

រីមៈ កាលហ្នឹងវាខ្វះខាតហូបចុកពិតមែនជំនាន់ហ្នឹង ហូបបបរអីចឹងទៅ ។

វណ្ណៈ៖ តែទ័ពដូចជាមិនអីទេពូ?

រីមៈ ទ័ពបើនៅជួរមុខអត់អីទេ តែបើនៅក្រោយហូបបបរអីហ្នឹង ។

វណ្ណៈ៖ ចឹងពូមានដឹងថាប្រជាជនត្រូវគេយកទៅសម្លាប់ឬអត់អាហារអីមានដឹងទេ?

រីមៈ ជំនាន់ហ្នឹងបានដឹងដែរតើ ខ្លះអ្នកណាដេលពាក់ព័ន្ធមានខ្សែរយៈចឹងទៅគេយកទៅសម្លាប់ទៅ ។

វណ្ណៈ៖ ចឹងប្រធានបន្ទាប់ៗដែលគ្រប់គ្រងពូផ្ទាល់តែម្តងពូមានដឹងទេ?

រីមៈ ស្គាលតែគាត់ស្លាប់អស់ហើយ ។

វណ្ណៈ ឈ្មោះអីខ្លះទៅ?

រីមៈ ដល់ក្រោយមកឈ្មោះ វៀន គាត់លាវទេនិងប្រធានកងពលខ្ញុំក្រោយ ។

វណ្ណៈ ចឹងកាលហ្នឹងពូជាយុទ្ធជនឬមួយដឹកនាំក្រុមអីវរៈសេនាតូចវរៈសេនាធំអីដែរ?

រីមៈ ដឹកនាំខ្លះដែរ អនុសេនាតូច ។

វណ្ណៈ ចឹងពូប្រធានអនុសេនាតូច?

រីមៈ បាទ ។

វណ្ណៈ ប្រធានអនុសេនាតូចហ្នឹងកាន់ប៉ុន្មាននាក់?

រីមៈ ហ្នឹងគេកាន់៥០នាក់អត់ទេ អាហ្នឹង៣០នាក់ទេ ។

វណ្ណៈ ចឹង៣០នាក់ទេ?

រីមៈ បាទ ។

វណ្ណៈ ចឹងបើប្រធានអនុសេនាធំ?

រីមៈ អនុសេនាធំអាហ្នឹងចូល៩០នាក់ហើយ ។

វណ្ណៈ បើតាមពូសង្កេតមើលទៅកាលហ្នឹងខាងតាកែវមិនខាងនិរតីពូណើស?

រីមៈ បាទ ។

វណ្ណៈ កាលដែលពូទៅធ្វើនៅមណ្ឌលគីរីហ្នឹង តើមានលាយអ្នកមកពីខាងកំពង់ចាមឬមកពីខេត្តផ្សេងៗបញ្ចូលគ្នាឬអត់មានទេ?

រីមៈ គេលាយគ្រប់ខេត្ត ។

វណ្ណៈ ចឹង?

រីមៈ បាទ!មានខាងខេត្តឧត្តរមានជ័យបើនិយាយរួមទៅគ្រប់ខេត្ត ។

វណ្ណៈ ចឹង?

រីមៈ កំពង់ចាមក៏មានមណ្ឌលគីរីនិងក៏មានបើនិយាយទៅទ័ពរួមគ្នាលាយគ្នា ។

វណ្ណៈ ទ័ពបូព៌ាក៏មានដែរ?

រីមៈ បាទ ។

វណ្ណៈ ចឹងក្រោយមកទៀតតា ម៉ុកអីមានដែលទៅលេងដល់ហ្នឹងទេ?

រីមៈ តា ម៉ុកជំនាន់ហ្នឹងដែលគាត់នៅដល់ខ្ញុំឡើងមកដល់ភ្នំដងរែកបាននៅខាងគាត់ ។

វណ្ណៈ អាហ្នឹងក្រោយមកទៀតទេ?

រីមៈ បាទ ។

វណ្ណៈ តែខ្ញុំចង់និយាយថាកាលសម័យប៉ីឆ្នាំណាស់?

រីមៈ តា ម៉ុកមាននៅមណ្ឌលគិរីដូចជាអត់ដឹង ។

វណ្ណៈ នៅមណ្ឌលគិរីពូមានដឹងថាប្រជាជនមានស្លាប់មានអីចឹងដែរ ពូនៅក្នុងសម័យហ្នឹងដែលដូចជាជនជាតិអីម៉េចដែរហូបជាសហករណ៍ដូចគ្នា?

រីមៈ បាទ!ហូបសហករណ៍សម័យហ្នឹងគេធ្វើសហករណ៍ កាលសម័យប៉ីឆ្នាំគេធ្វើជាសហករណ៍ឆ្នាំងធំឆ្នាំងរួមចឹងហើយ ។

វណ្ណៈ ចឹងជនជាតិហ្នឹងក្រោយរបនាសម្ព័ន្ធរបស់ប៉ុល ពតដែលអត់មានសេរីបានទេ?

រីមៈ អត់ទេ ដូចគ្នា ។

វណ្ណៈ ចឹងជនជាតិអត់មានរើបំរះតវ៉ាប្រឆាំងអីទេ?

រីមៈ អត់ហ៊ានតវ៉ាប្រឆាំងទេ សម័យហ្នឹងតវ៉ាប្រឆាំងគេសម្លាប់ ។

វណ្ណៈ ចឹងទោះបីជាជនជាតិក៏ខ្លាចដែរ?

រីមៈ បាទ!ធ្វើយ៉ាងម៉េចដើម្បីរស់ ។

វណ្ណៈ តែជនជាតិវាស្លៀកពាក់ខ្មៅដែលឬស្លៀកពាក់យ៉ាងម៉េច?

រីមៈ សម័យហ្នឹងស្លៀកពាក់ខ្មៅ ។

វណ្ណៈ អង្គការចែកឲ្យ?

រីមៈ អង្គការចែកឲ្យតែតាមប្រភេទគេដែលគេធំគេមានខោអាវពណ៌អីចឹងទៅ ។

វណ្ណៈ ចឹងពូនៅមណ្ឌលគិរីរហូត?

រីមៈ ខ្ញុំនៅឆ្នាំ៨២បានខ្ញុំមកដល់ភ្នំដងរែក ។

វណ្ណៈ ចឹងពេលគេចប់ភ្នំពេញនៅពេលវៀតណាមវាចូលមក ចឹងទៅនៅមណ្ឌលគិរីមានការភ្ញាក់ផ្អើលមានដឹងថាស្រុកទេសគេចប់សង្គ្រាមមានដឹងទេ?

រីមៈ បាទ!ដឹងតើគេផ្សាយតាមវិទ្យុចឹងដូចថាក្នុងក្រុមក្នុងកង គេដឹកនាំចូលព្រៃក៏ចូលតាមគេទៅចូលតស៊ូក្នុងព្រៃចឹងទៅ ។

វណ្ណៈ ចឹងហេតុអីពូគិតថាជិតចប់ហើយ ចង់មករកឪពុកម្តាយស្រុកទេសជួបបងប្អូនអីហេតុអីបានជាពូមិនត្រឡប់មក?

រីមៈ ជំនាន់ហ្នឹងនេះនិយាយការពិតទៅអ្នកដឹកនាំគេចេះតែឃោសនា គេថាឥឡូវមិនបាច់ទៅស្រុកទៅភូមិទេ ទៅខ្លាចយួនសម្លាប់អីចេះចុះទៅ ចឹងចេះតែនាំគ្នាប្រឹងតស៊ូនៅក្នុងព្រៃចឹងទៅ ។

វណ្ណៈ ចឹងកាលជំនាន់បីឆ្នាំពូមានបានទៅលេងស្រុកទេ?

រឹមៈ អត់បានទេ ។

វណ្ណៈ យ៉ាងម៉េចបានជាពូមិនបានមកលេងស្រុក?

រឹមៈ គេមិនឲ្យមក ។

វណ្ណៈ ចឹងគេមិនឲ្យមក?

រឹមៈ បាទ!មិនឲ្យ ។

វណ្ណៈ ចឹងពូធ្លាប់សុំដែរ?

រឹមៈ អត់ទេ សុមយ៉ាងណាក៏មិនឲ្យមក គេមានគេធ្លាប់សុំតែខ្ញុំមិនបានសុំទេ តែមានគេអ្នកសុំ គេសុំមិនបានពេលហ្នឹង គេមិនឲ្យមកគេថាមិនទាន់ដល់ឆ្នាំដល់ខែត្រូវមក ។

វណ្ណៈ ប្រហែលជាខ្លាចបែកការណ៍ឬមួយយ៉ាងម៉េច បើតាមពូគិតណាស់?

រឹមៈ តាមគិតទៅអានេះបើតាមគំនិត ខ្ញុំនេះក៏គេមិនឲ្យមកដែលព្រោះថាដល់មកដល់ខាងសហករណ៍ភូមិស្រុកចឹងទៅមកឃើញឪពុកម្ដាយអត់បាយអត់ទឹកចឹងដូចថាវាអស់ស្មារតីប្រយុទ្ធចឹងទៅណាស់ដល់ចឹងគេមិនឲ្យយើងមកទេ ។

វណ្ណៈ បាទ! ដល់ចឹងពូដូចជានៅមណ្ឌលគិរីហ្នឹងសម័យហ្នឹងក្រៅពីកងពលអីហ្នឹងដូចជាគណៈតំបន់ គណៈស្រុកពូដឹងថាពីណាគេជាអ្នកគ្រប់គ្រង គណៈភូមិភាគ?

រឹមៈ គណៈភូមិភាគកាលហ្នឹងខ្ញុំអត់យល់ដែរ ។

វណ្ណៈ ចឹងតា ពកអីអត់ទៅខាងហ្នឹងទេ?

រឹមៈ តា ពកគាត់អត់ទៅខាងហ្នឹងទេ តា ពកខាងកំពង់ចាម ។

វណ្ណៈ បាទ ។

រឹមៈ ភូមិភាគទៅខាងហ្នឹងខ្ញុំអត់យល់ អត់ស្គាល់ ។

វណ្ណៈ ចឹងគណៈតំបន់?

រឹមៈ ឈ្មោះ ហមហ្នឹងគេហៅឈ្មោះដើមឈ្មោះហម ឈ្មោះគាត់ក្នុងបញ្ជីរជាតិ ឈ្មោះឡាំង ។

វណ្ណៈ ចឹងឈ្មោះឡាំង?

រឹមៈ ឈ្មោះ អ៊ឹ ឡាំង ។

វណ្ណៈ ចឹងគណៈស្រុក?

រឹមៈ គណៈស្រុកឈ្មោះអីទេ ភ្លេចឈ្មោះគាត់ហើយយូរហើយឈ្មោះ សា រ៉ុន អ៊ឹ សារ៉ុន ។

វណ្ណៈ ចឹងអ្នកប៉ុន្មាននាក់ហ្នឹងគេចាប់ខ្លួនទេក្រោយមក?

រីមៈ ក្រោយមកគេអត់មានចាប់ខ្លួនគាត់នៅដល់សព្វថ្ងៃ គាត់នៅអន្លង់វែងសព្វថ្ងៃហ្នឹង ។

វណ្ណៈ តា សារ៉ុនហ្នឹង?

រីមៈ បាទ ។

វណ្ណៈ គាត់ឈ្មោះស្អី សារ៉ុនទៅ?

រីមៈ អត់ស្គាល់នាមត្រកូលគាត់ ។

វណ្ណៈ ចឹងហម ហៅឡាំងនេះនៅទេ?

រីមៈ អត់ទេ ហ្នឹងគេសម្លាប់គាត់តាំងពីសម័យកសាងនោះ តាំងសម័យបីឆ្នាំនោះ ។

វណ្ណៈ ឆ្នាំណាដែលគេចាប់គាត់?

រីមៈ ខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ ប្រហែលជា៧៧ឬ៧៨?

រីមៈ ជំនាន់ហ្នឹងប្រហែលជា៧៨ ឆ្នាំ៧៨ហ្នឹង ។

វណ្ណៈ ចឹងពេលសម្លាប់ហមហើយមានពីណាចូលមកទៀត?

រីមៈ ដល់ក្រោយមកហ្នឹងមានអ៊ឹ សា រ៉ុនហ្នឹងហើយ ។

វណ្ណៈ ចឹងក្រោយមកផ្លាស់មកអ៊ឹ សា រ៉ុនហ្នឹងតែម្តង?

រីមៈ បាទ ។

វណ្ណៈ ចឹងសា រ៉ុនសព្វថ្ងៃនៅអន្លង់វែង?

រីមៈ បាទ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៨២ពូចេញពីមណ្ឌលគិរីមកអន្លង់វែង?

រីមៈ ពីមណ្ឌលគិរីមកឡើងនៅខាងទៅយើងខាងមុំបីជាប់ព្រំដែនលាវនោះ គេហៅនៅខាងទន្លេអំពៅ ។

វណ្ណៈ ចឹងនៅជាប់ព្រំដែនលាវ?

រីមៈ បាទ ។

វណ្ណៈ ពីណាគ្រប់គ្រងកាលនៅមុំបី?

រីមៈ ទទួលរួមកាលហ្នឹង កាលហ្នឹងខ្ញុំនៅកងវរៈសេនាធំឯករាជ្យខ្ញុំនៅជាមួយតា សុន សេនហ្នឹងតែម្តង ។

វណ្ណៈ ចឹង?

រីមៈ តែមិននៅជាមួយគាត់ផ្ទាល់ទេ នៅជុំវិញគាត់ហ្នឹង ។

វណ្ណៈ	ចឹងនៅក្រោមការគ្រប់គ្រងរបស់តា សុន សេន?

រីមៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកទៀតឆ្នាំ៨២-៨៣-៨៤-៨៥ពូនៅណាដែរ?

រីមៈ	ខ្ញុំនៅហ្នឹងរហូតដល់ឆ្នាំ៨៥ដល់វៀតណាមវៃបុកផ្តាច់ភ្នំដងរែកបានមកយើងខាងអន្លង់វែង និយាយទៅជិតនាន់និងហើយភាសខ្លួននៅស្រុកថៃតែម្តង នៅក្នុងទឹកដីថៃ ។

វណ្ណៈ	ចឹងក្រោយមករត់ទៅជំរំទៀត?

រីមៈ	អត់ត្រូវទៅជំរំទេ កាលពីដើមនិយាយទៅខាងខ្មែរក្រហមហ្នឹងអត់មានជំរំទេ គឺនៅជាប់ព្រំដែនខ្មែរយើងហ្នឹង ។

វណ្ណៈ	ចឹងអត់មានជំរំទេ?

រីមៈ	បាទ!អត់មានជំរំទេ ។

វណ្ណៈ	ប៉ុន្តែពូថាឆ្នាំ៨៥ នៅលើទឹកដីថៃ?

រីមៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹងមានវៃជាមួយវៀតណាមអីយ៉ាងម៉េចដែលពូ ហើយសម្ភារបានមកពីខាងណាដែរ?

រីមៈ	សម័យហ្នឹងសម្ភារអាវុធគ្រាប់អីហ្នឹងបានមកពីចិនគេជំនួយឲ្យមកហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមានចិនជួយ?

រីមៈ	បាទ ។

វណ្ណៈ	ចឹងពេលវៃហ្នឹងពូមានឃើញសកម្មភាពស្លាប់រស់អីយ៉ាងម៉េចដែរ?

រីមៈ	អាហ្នឹងវាស្លាប់ទាំងសងខាងហ្នឹងព្រោះថា បាចទឹកដាក់គ្នាតែងតែមានគ្រោះថ្នាក់ហើយ ។

វណ្ណៈ	ចឹងកាលដែលពូវៃខ្លាំងនៅអន្លង់វែងអីហ្នឹងពីណាគ្រប់គ្រងវិញ នៅក្រោមបញ្ជារបស់តា ម៉ុក ឬមួយយ៉ាងម៉េច?

រីមៈ	កាលជិនាន់ខ្ញុំនៅសម័យហ្នឹង ក្រោមបញ្ជារបស់តា សុន សេនតែម្តង ។

វណ្ណៈ	កាលនៅអន្លង់វែង?

រីមៈ	កាលនៅអន្លង់វែងនៅក្រោមបញ្ជារបស់ តា សុន សេនហ្នឹងដែរ ព្រោះគាត់ទទួលរួមនោះ ។

វណ្ណៈ	ចឹងតា ម៉ុក កាន់អីវិញ?

រីមៈ	តា ម៉ុក គាត់ខាងយោធាគាត់ក៏ទទួលរួមដែរ ថាគេមានជាន់ថ្នាក់គេ ។

វណ្ណៈ	ចឹងជាមួយសុន សេនហ្នឹង?

រីមៈ	បាទ ។

វណ្ណៈ	ចឹងតាមពូគិតមើលសុន សេននិងតា ម៉ុកគាត់មានគំនិតខុសគ្នាដែលអត់កន្លងមក?

រីមៈ	កន្លែងហ្នឹងខ្ញុំអត់យល់ដែរ ខ្ញុំក្តាប់មិនបានដែលព្រោះមិនបានចូលទៅជិតគាត់ ខ្ញុំនៅខាងក្រៅនៅជុំវិញ ។

វណ្ណៈ	ចឹងពូនៅអន្លង់វែងហើយពូទៅនៅណាទៀតដែរ?

រីមៈ	នៅអន្លង់វែងហើយដល់ក្រោយមកបានគេ បានតា សុន សេនគាត់មកនេះបានគាត់យកពួកខ្ញុំហ្នឹងមកនេះ ។

វណ្ណៈ	ឆ្នាំណាពូមកនេះ?

រីមៈ	ឆ្នាំ៩០ប៉ុន្មានទេ ដូចជា៩២ក្លេចដែលទៅ បើមិន៩១-៩២ហ្នឹងមកនៅនេះ ។

វណ្ណៈ	ចឹងគាត់យកកងទ័ពមកមួយចំនួនចឹង?

រីមៈ	បាទ!យកកងទ័ពមកមួយចំនួនទាំងអស់មាន៥០០គ្រួសារមកនៅនេះ តាំងពីជំនាន់អ៊ុនតាក់ចូលមកហ្នឹងមកនៅភូមិអូរគីគីរដល់បច្ចុប្បន្ននេះ ។

វណ្ណៈ	ចឹងនៅខាងភូមិអូរគីគីរពីមុនមកខាងតា សុខ គង់គាត់គ្រប់គ្រងនៅភូមិនេះ?

រីមៈ	បាទ!កន្លែងនេះស្រុកកំរៀងតា សុខ គង់ហ្នឹងឯងគាត់គ្រប់គ្រង ។

វណ្ណៈ	បាទ!ចឹងនៅពេលតា សុន សេនយកមកដាក់ទៀតចឹងអត់មានបញ្ហាអីទេ?

រីមៈ	ដូចជាមិនមានបញ្ហាអី ព្រោះគាត់តា សុខ គង់ហ្នឹងនៅក្រោមបញ្ជារបស់តា សុន សេនដែរ ព្រោះតា សុន សេនគាត់ជាអគ្គមេបញ្ជាការរួមហើយ ។

វណ្ណៈ	ចឹងតា សុន សេនហ្នឹងគាត់មានបំផុសចលនាធ្វើទ័ពអីរបៀបម៉េចដែរ?

រីមៈ	និយាយទៅអ្នកដឹកនាំសម័យនេះ គេចេះតែឃោសនាគេថាឥឡូវយើងត្រូវការពារទឹកដីកុំឲ្យយួនចូលឈ្លានពានទឹកដីខ្មែរយើងប៉ុណ្ណឹង ។

វណ្ណៈ	បាទ ។

រីមៈ	ដល់ចឹងចេះតែបំផុសចលនាចឹងទៅ ចេះនាំគ្នាតស៊ូចឹងទៅព្រោះខ្លាចបាត់បង់ទឹកដី ។

វណ្ណៈ	ចឹងកាលដែលពូចូលមកនៅឆ្នាំ៩២-៩៣ហ្នឹងនៅមានព្រៃទេ?

រីមៈ	សម័យ៩២ហ្នឹងសុទ្ធតែព្រៃទាំងអស់ ។

វណ្ណៈ	ចឹងអត់ទាន់មានពីណាកាប់ទេ?

វីមៈ បាទ!អត់មានពីកាប់ទេ សុទ្ធតែព្រៃឫស្សីអីព្រៃឈើហ្នឹងទាំងអស់ មិនទាន់មានវាលមានភូមិអីទេ ។

វណ្ណៈ ចឹងមិនទាន់មានវត្តវាអីទេ?

វីមៈ បាទ!មិនទាន់មានទេ ព្រៃសុទ្ធសាធតែម្តង ។

វណ្ណៈ តែមានប្រជាជនរស់នៅច្រើនទេពូ?

វីមៈ កាលមកពីអន្លង់វែងហ្នឹង៥០០គ្រួសារ តែបែកគ្នាតាំងពីភូមិថ្មីមករបូតមកផុតត្រឹមភូមិអូរគគីរនេះ ។

វណ្ណៈ បាទ ។

វីមៈ ទៅខាងមុខទៀតមិនមានទេ ។

វណ្ណៈ ចឹងកាលពូមកហ្នឹងមានប្រជាជនខ្លះនៅទីនេះហើយមានទ័ពខ្លះនៅហ្នឹងដែរ?

វីមៈ អត់មានទេ ។

វណ្ណៈ ចឹងទ័ពរបស់តា គង់នៅនោះ?

វីមៈ អាហ្នឹងគេនៅខាងនោះទេ គេនៅចាប់ត្រឹមផ្លូវបំបែកអាវុធហាត់មកនេះ អាផ្លូវទៅកំរៀងហ្នឹង ។

វណ្ណៈ បាទ ។

វីមៈ គេមានតែខាងហ្នឹងទេ ហើយមានទៅខាងភូមិកំរៀង ។

វណ្ណៈ បាទ ។

វីមៈ ចាប់ពីផ្លូវបំបែកមកនេះ អត់មានភូមិស្រុកអីទេ សុទ្ធតែព្រៃទាំងអស់ ។

វណ្ណៈ ចឹងនៅហ្នឹងនិយាយទៅកើតភូមិកើតអីចឹងតាំងពីឆ្នាំណាមក?

វីមៈ កើតភូមិចាប់ពីពួកខ្ញុំមកកាលឆ្នាំ៩២ហ្នឹងកើតនៅនេះតែម្តង ។

វណ្ណៈ ចឹងកាលមកដំបូងនៅតាមមាត់អូរទេ?

វីមៈ បាទ!នៅតាមមាត់អូរសុទ្ធតែព្រៃ កាលហ្នឹងនៅតាមនេះអត់មានទឹកនោះ ។

វណ្ណៈ បាទ ។

វីមៈ ដល់ចឹងទៅរស់នៅតាមមាត់អូរ តាមមាត់អូរដារយើងនេះ ។

វណ្ណៈ បាទ ។

វីមៈ ចឹងកាលហ្នឹងសង់ខ្ទមអីនៅតូចតាចចឹងទៅ តាមកងតាមក្រុមចឹងទៅ ។

វណ្ណៈ ចឹងកាលហ្នឹងពូឃើញថាទំរាំធ្វងកាត់បានប៉ុណ្ណឹងពូឃើញថាជួបការលំបាកអ្វីខ្លះដូចចាញ់ឬមួយឈឺស្លាប់មនុស្សជាច្រើនទៀតឬមួយយ៉ាងម៉េចពូ ក្រោយ៧៩ហ្នឹង?

រីមៈ ក្រោយហ្នឹងមកអ្នកគស្ញ័ដូចជាជួបការលំបាក ដូចថាវាឆ្អែតឆ្អល់អស់ហើយវាជួបការលំបាកដូចថាវាជួរចត់ពេករឿងការលំបាកហ្នឹង ដល់ចឹងចេះតែទ្រាំទៅមិនដឹងជាធ្វើម៉េច ។

វណ្ណៈ បាទ ។

រីមៈ រឿងឈឺស្លាប់របួសស្លាប់អីចឹងទៅជាការធម្មតាវិញដល់ពេលយូរៗទៅ ។

វណ្ណៈ ចឹងមានឈឺគ្រុនចាញ់ជាន់មីនជាន់អីដូចគ្នា?

រីមៈ បាទ!នៅព្រៃនេះជាព្រៃតំបន់មីនដែលដល់ចឹងមានស្លាប់មានរបួសចឹងទៅវាធ្លាប់ច្បាំងពីដើមមកដល់ចឹងការស្លាប់អីជាការធម្មតាទៅវិញ ។

វណ្ណៈ បាទ!ចឹងនៅភូមិដូងម៉ាឡៃអីពូមិនបានចូលទេ ពួមកនេះតែម្តងពូចេញពីអន្លង់វែងមកនេះតែម្តង?

រីមៈ បាទ ។

វណ្ណៈ ចឹងកាលពូនៅទ័ពហ្នឹងខាងកងទ័ពខ្មែរក្រហមកាលហ្នឹងមានផ្តល់ប្រាក់ខែអីឲ្យទេ?

រីមៈ អត់មានទេ អត់មានប្រាក់ខែទេ ។

វណ្ណៈ ចឹងពូមានគ្រួសារចាប់ពីពេលណាមក?

រីមៈ ខ្ញុំមានគ្រួសារតាំងពីឆ្នាំ៧៧នោះ ។

វណ្ណៈ តាំងពីឆ្នាំ៧៧?

រីមៈ បាទ!តាំងពីសម័យបីឆ្នាំ ។

វណ្ណៈ អង្គការរៀបឲ្យ?

រីមៈ អង្គការរៀបឲ្យ ។

វណ្ណៈ ចឹងកាលឆ្នាំ៧៧ហ្នឹងពូនៅស្នើឬមួយចាប់ដាក់ៗ?

រីមៈ ហ្នឹងដូចថាសម័យហ្នឹង គេឲ្យរើសស្រឡាញ់ដូចថានារី“ក”ចឹងទៅដល់ហើយគេសួរខាងនារី“ក”បើថាគេស្មគ្រ័ចិត្តយកពូ“ខ”ចឹងទៅដល់ចឹងមានកិច្ចព្រមព្រៀងគ្នាចឹងទៅគេសួរទៅវិញទៅមកថាស្រឡាញ់គ្នាក៏អង្គការគេរៀបឲ្យទៅ ។

វណ្ណៈ ចឹងអត់មានបង្ខំទេ?

រីមៈ បាទ!អត់មានបង្ខំទេ ដូចតែស្មគ្រ័ចិត្តដែលទេ ។

វណ្ណៈ ចឹងការហ្នឹងមានតំណាងអីខ្លះទេ?

រីមៈ បាទ ។

វណ្ណៈ ចង់និយាយថាពូការហ្នឹងមានពិធីជប់លៀងអីខ្លះទៅ?

រីមៈ មានដែលតើ តែការសម័យហ្នឹងអត់មានម្នាក់ពីរនាក់ទេ ការសឹងថាម៉ាអនុសេនាតូច កាលដែលខ្ញុំការហ្នឹងមាន២០គូរដាងនោះ២៥ទៅ២៦គូរ តែការសម័យហ្នឹងការដូចជាអង្គុយប្រជុំគ្នាដូចជាអង្គុយក្នុងតុគេណែនាំចឹងទៅតែគេមានពិធីជប់លៀងកាប់ជ្រូកអីចឹងដែរ ហូបអាហារមួយពេលចឹងទៅ ។

វណ្ណៈ ចឹងមានខ្លះមិនពេញចិត្តអីទេ?

រីមៈ មានអ្នកខ្លះមិនពេញចិត្តដែលហ្នឹងអ្នកខ្លះ តែក្រោយមកខ្លះក៏បែកបាក់គ្នាខ្លះអ្នកណាមិនស្រឡាញ់ប្ដីអីចឹងទៅមានបែកបាកគ្នាចឹងទៅ តែគេអត់យកទៅធ្វើបាបទេ ។

វណ្ណៈ បែកបាក់និងចង់និយាយថាបែកបាកក្រោយមកទៀត នៅពេលហ្នឹងមិនហ៊ានទេ?

រីមៈ បាទ ។

វណ្ណៈ ចឹងពេលដែលអង្គការរៀបឲ្យនិងមិនហ៊ានបែកបាក់ទេគឺនៅជាមួយគ្នា?

រីមៈ បាទ ។

វណ្ណៈ ចឹងនៅក្រោយ៧៩មកខ្លះលែងគ្នាខ្លះវិញចឹងមែនទេពូ?

រីមៈ បាទ!ខ្លះក៏លែងគ្នាទៅខ្លះក៏យកគ្នាទៅ ។

វណ្ណៈ ចឹងខ្លះយកគ្នាដល់រហូតរាល់ថ្ងៃទៅ?

រីមៈ បាទ!ដូចជាគ្រួសារខ្ញុំសព្វថ្ងៃនេះគឺជាប់គ្នារហូតទាល់សព្វថ្ងៃ ។

វណ្ណៈ ចឹងពូបានស្នេហ៍គ្រប់ទាំងអស់គ្នា?

រីមៈ បាទ ។

វណ្ណៈ ចឹងមកដល់ឥឡូវហ្នឹងពូធ្លាប់ទៅលេងស្រុកកំណើតបានប៉ុន្មានដង?

រីមៈ ខ្ញុំទៅប្រហែលជា៥ដងហើយ ព្រោះសម័យនេះយើងស្រួលទៅស្រួលមក ។

វណ្ណៈ ចឹងបងប្អូនពូនៅស្រុកឬមួយក៏នៅនេះខ្លះហើយ?

រីមៈ នៅស្រុកទាំងអស់ ។

វណ្ណៈ ចឹង?

រីមៈ បាទ ។

វណ្ណៈ ចឹងនៅពេលទៅលេងម្ដងៗពូមានអារម្មណ៍សប្បាយដែរ?

រីមៈ បានសប្បាយជួបជុំបងប្អូនបានសប្បាយ ។

វណ្ណៈ	ចឹងពូមកនៅនេះមកដល់សព្វថ្ងៃនេះពូមានបំណងចង់ទៅស្រុកកំណើតវិញឬមួយមិនមានទេ?

រីមៈ	អត់ទេ គោលបំណងខ្ញុំមិនចង់ទៅរស់នៅស្រុកកំណើតវិញទេ គឺមានទឹកមានដីនៅនេះហើយ អត់មានទៅស្រុកកំណើតវិញទេ ព្រោះថាទៅរស់នៅស្រុកកំណើតដីវាចង្អៀតខ្លាំងណាស់ ។

វណ្ណៈ	បាទ ។

រីមៈ	សូម្បីទៅលេងស្រុកម្តងៗ ឃើញកន្លែងទីលំនៅពីដើម នៅដីវាលល្ហល្ហេវឥឡូវនេះវាសុទ្ធតែផ្ទះ សុទ្ធតែសំប៉ែង រកតែកន្លែងកាប់ខ្មោចគ្មានវាសុទ្ធតែផ្ទះទាំងអស់ហើយឥឡូវសព្វថ្ងៃ ចឹងបាន មិននៅស្រុកនៅអីហ្នឹង អ្នកអត់អ្នកក្រអីហ្នឹងគ្មានដីកប់ទេ ដល់ចឹងខ្មោចដែលស្លាប់ទៅសុទ្ធតែ បូជា ដល់ចឹងដីចង្អៀតណាស់ខាងស្រុកកំណើត មកខាងនេះដីវាទូលាយ ។

វណ្ណៈ	បាទ ។

រីមៈ	ចឹងបានថាចិត្តចង់ទៅរស់នៅស្រុកកំណើតមិនមានចង់ទេ ។

វណ្ណៈ	ចឹងពូនៅនេះកកើតភូមិហើយអស់ព្រៃឈើទូលំទូលាយតែម្តងនៅឆ្នាំណា សមាហរណ៍កម្ម ហើយឬមុនសមាហរណ៍កម្ម?

រីមៈ	ក្រោយសមាហរណ៍កម្មហើយចាប់ផ្តើមរុករានដីដីចឹងទៅ ដីចំការដីស្រែចឹងទៅ ។

វណ្ណៈ	ចឹងក្រោយសមាហរណ៍កម្មអស់ព្រៃ?

រីមៈ	បាទ ។

វណ្ណៈ	ឈើហ្នឹងយើងកាប់លក់ឲ្យថៃឬមួយយើងកាប់ធ្វើផ្ទះសំប៉ែងឬមួយយកទៅដោះដូរអី?

រីមៈ	ដំនាន់កាលសម័យហ្នឹងកាប់លក់ឲ្យថៃខ្លះចឹងទៅ ធ្វើផ្ទះចឹងខ្លះទៅ ដើម្បីយកប្រាក់និងមក ចិញ្ចឹមជីវិត ។

វណ្ណៈ	ចឹងប្រជាជននៅស្រុកនេះមករស់តាំងពីឆ្នាំ៩០-៩១-៩២ទាំងអស់គ្នាចឹងតែម្តងជាហូរ ហែរមកតែម្តងភូមិនេះ?

រីមៈ	បាទ!តែកាលឆ្នាំ៩២ពួកខ្ញុំមកតែចំនួន៥០០គ្រួសារទេ តែមកបច្ចុប្បន្ននេះមានច្រើន ច្រើនអ្នកចំណូលមកខ្លះគេមកនៅតាមបងប្អូនគេចឹងទៅមកពីស្រុក គេមករស់នៅនេះចឹងវា បានបន្តុបន្តើតទៅជាច្រើនគ្រួសារឡើងរាប់រយរាប់ពាន់គ្រួសារហើយនៅឃុំអូរដារនេះ ។

វណ្ណៈ	បាទ ។

រីមៈ	កាលពីដើមមានតិចទេ ។

វណ្ណៈ	បាទ!ចឹងពូនៅនេះពូមានស្គាល់តា អានទេ?

រីមៈ	អឺអាន?

វណ្ណៈ បាទ ។

រីមៈ អឺអាននៅត្រង់នេះហ្នឹង ។

វណ្ណៈ បាទ ។

រីមៈ ស្គាល់គាត់មកពីហ្នឹងដូចគ្នា ។

វណ្ណៈ ចឹងគាត់មកពីហ្នឹងដូចគ្នា?

រីមៈ បាទ ។

វណ្ណៈ ចឹងតា អានគាត់មកពីអន្លង់វែងជាមួយពូដែរ?

រីមៈ បាទ!អត់ទេ អឺអានគាត់មកក្រោយទេ ។

វណ្ណៈ ចឹងគាត់មកក្រោយទៀតប្រហែលជាឆ្នាំណា?

រីមៈ ខ្ញុំមិនដឹងដែលខ្ញុំភ្លេចហើយគាត់មកឆ្នាំប៉ុន្មាន ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយបានគាត់មកឬមួយគាត់មកមុនសមាហរណ៍កម្ម?

រីមៈ មកក្រោយនិងទៀត ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយមិនទាន់មកទៀត?

រីមៈ បាទ!សមាហរណ៍កម្មហើយបានប្រហែលជាបីបួនឆ្នាំដែលបានគាត់មក ខ្ញុំភ្លេចដែលហ្នឹងមិនបានចាំ ។

វណ្ណៈ ចឹងពូមានបានដឹងតា អាននៅក្នុងសម័យបីឆ្នាំគាត់ធ្វើអីដែលទេ?

រីមៈ កាលសម័យបីឆ្នាំគាត់ធ្វើធំដែលហ្នឹង កាលហ្នឹងដូចថាគាត់មនុស្សចាស់ទុំដូចជាព្រឹទ្ធាចារ្យមួយនៅក្នុងហ្នឹងដូចថា ជំនាន់ហ្នឹងគាត់ធ្វើធំដែលហ្នឹងជំនាន់ហ្នឹង ។

វណ្ណៈ ឋានៈគាត់ត្រឹមណា?

រីមៈ បើប្រៀបធៀបទៅគាត់ តែកាលហ្នឹងគាត់នៅទន្លេល្ពៅកាលហ្នឹងដូចគាត់ទទួលរួមមួយភូមិធំចឹងទៅ ។

វណ្ណៈ ភូមិនៅណាគាត់កាន់កាប់នៅណាវិញ?

រីមៈ ជំនាន់ហ្នឹងយើងនៅក្នុងដីថៃទេ ។

វណ្ណៈ អត់ទេ ខ្ញុំចង់និយាយថាជំនាន់ខ្មែរក្រហម?

រីមៈ កាលជំនាន់ខ្មែរក្រហមហ្នឹងគាត់នៅ ។

វណ្ណៈ ជំនាន់បីឆ្នាំហ្នឹងគាត់នៅណា?

រីមៈ កាលហ្នឹងគាត់ក្តាប់រួមនៅទន្លេល្ពៅ ។

វណ្ណៈ ទន្លេល្ពៅខេត្តណាទៅ?

រីមៈ ទន្លេល្ពៅកន្លែងមុំបីហ្នឹង ។

វណ្ណៈ មុំបីនៅស្ទឹងត្រែង?

រីមៈ ហ្នឹងមិនមែនស្ទឹងត្រែងទេ ព្រះវិហាហ្នឹងត្រង់ហ្នឹង ។

វណ្ណៈ ចឹង?

រីមៈ បាទ! ខាងមុំបីខាងព្រះវិហារទេខាងហ្នឹង ។

វណ្ណៈ ចឹងតា អានគាត់ទៅគ្រប់គ្រងខាងព្រះវិហាកាលហ្នឹង?

រីមៈ កាលហ្នឹងគាត់ទទួលរួមខាងប្រជាជននៅក្នុងភូមិអ៊ឹ អានហ្នឹង កាលជំនាន់ហ្នឹងគេហៅភូមិអ៊ឹ អានៗហ្នឹង ។

វណ្ណៈ នៅកន្លែងណានៅខេត្តណា?

រីមៈ ហ្នឹងបីកាលហ្នឹងមានតែព្រះវិហារទេ ជាប់ខាងស្ទឹងត្រែងជាប់ខាងឡាវកាលហ្នឹង ។

វណ្ណៈ ជាប់ស្ទឹងត្រែងដែលមែនទេ?

រីមៈ បាទ ។

វណ្ណៈ ជាប់ព្រះវិហារទៀត?

រីមៈ កន្លែងហ្នឹងបើនិយាយទៅគេហៅខេត្តព្រះវិហាកន្លែងហ្នឹង ដល់ចុះពីហ្នឹងមកបានមកដល់ខេត្តស្ទឹងត្រែងបានមកជួបភ្នំកំបោរផ្លូវឆែបផ្លូវអីនេះហ្នឹងបានចូលទៅខាងស្ទឹងត្រែង ។

វណ្ណៈ ចឹងតា អានហ្នឹងគាត់ឈ្មោះអីអាន?

រីមៈ ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ចឹងហៅគាត់តែតា អានៗដែរ?

រីមៈ បាទ!គេហៅថាអ៊ឹ អានៗ ។

វណ្ណៈ កាលហ្នឹងគាត់ជាគណៈតំបន់ឬមួយជាគណៈស្រុកពូ តាមពូដឹងពូមានដឹងទេ?

រីមៈ ខ្ញុំមិនបានដឹងដែលគាត់ ។

វណ្ណៈ ចឹងមិនបានដឹងទេ?

រីមៈ បាទ ។

វណ្ណៈ តែដឹងថាគាត់ធ្វើធំ?

រីមៈ បាទ ។

វណ្ណៈ ចឹងសព្វថ្ងៃគាត់នៅភូមិអី?

វីមៈ គាត់នៅភូមិអូរ ផ្ទះគាត់នៅត្រង់នេះ ។

វណ្ណៈ ចឹងពូថាឥឡូវគាត់ចេះផ្សំថ្នាំលក់ដែរ?

វីមៈ បាទ ។

វណ្ណៈ ថ្នាក់គាត់លក់ពូកែទេ?

វីមៈ ថ្នាំគាត់ថ្នាំសរសៃអីបើគេហូបបាត់គ្រប់គ្នា គាត់ជាគ្រូទាចារ្យមួយដែរ ថ្នាំគាត់ពូកែដែលមើលមីងសៀងៗហ្នឹងពីដើមគាត់កើតមហារីកដោះ គាត់មើលជាតើគាត់មើលជាទាល់សព្វថ្ងៃ ។

វណ្ណៈ មហារីកមើលមិនងាយជាទេ ចឹងគាត់មានថ្នាំឫសដូងឈើក្បាលដែរ?

វីមៈ និយាយទៅគាត់ចេះច្រើនថ្នាំបុរាណ ។

វណ្ណៈ ចឹងឥឡូវគាត់មានថ្នាំលក់ទេ?

វីមៈ មានដែលតើ ដូចជាអ្នកសរសៃខ្ចីអីហ្នឹងតានេះទៅរកគាត់ហើយ ។

វណ្ណៈ ផ្ទះគាត់នៅម្ដុំណាដែរ?

វីមៈ ផ្ទះគាត់រំលងពីនេះទៅពីរបីផ្ទះហ្នឹង ។

វណ្ណៈ នៅខាងឆ្វេងដៃឬនៅខាងស្ដាំដៃ?

វីមៈ ទៅពីនេះខាងឆ្វេងដៃ មើលទៅពីនេះទៅមានផ្ទះពូ ងាមួយផ្ទះញ៉ាវ ផ្ទះប៉េងរំលងបីផ្ទះ ។

វណ្ណៈ បាទ!ចឹងរំលងបីផ្ទះដល់ផ្ទះគាត់ហើយ?

វីមៈ បាទ!មានផ្លូវមួយនោះមកកើតចេះផ្ទះគាត់នៅខាងនេះ ខាងនេះផ្លូវរទេះខាងនេះផ្លូវអាត្រាក់នៅខាងត្បូងហ្នឹង ។

វណ្ណៈ ចឹងពីគិតថានៅមុនសមាហរណ៍កម្មនិងក្រោយសមាហរណ៍កម្មពីគិតថា នៅសម័យតស៊ូនិងសម័យឥឡូវមួយណាស្រួលរស់នៅជាងឬមួយយ៉ាងម៉េច នៅក្នុងអារម្មណ៍របស់ពូផ្ទាល់?

វីមៈ កាលពីសង្គ្រាមនិងក្រោយសមាហរណ៍កម្មមក ឃើញថារាល់ថ្ងៃនេះឃើញស្រួលយើងរកស៊ីតាមចិត្តគំនិតរបស់យើងស្រួលបានមិនដូចពីដើម ពីដើមរកស៊ីអីមិនបានទេ សព្វថ្ងៃនេះគឺស្រួលណាស់ ។

វណ្ណៈ យើងរកបានប៉ុន្មានហូបប៉ុណ្ណឹង?

វីមៈ បាទ ។

វណ្ណៈ ចឹងអត់មានពីណាមកប្រមូលអីទេ?

វីមៈ បាទ!អត់មានពីណាមកប្រមូលមកបង្ខំអីទេ ។

វណ្ណៈ៖ ចឹងពូថានៅឆ្នាំណាដែលថា សុន សេនចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិគោរទេះអីហ្នឹងយកទៅដាក់រួមអីហ្នឹងនៅភូមិហ្នឹងឆ្នាំណាពូមានដឹងទេ?

រីមៈ នៅនេះដូចជាមិនមានទេ បើមាន មានកាលសម័យកសាងសម័យមុនកាលសម័យបីឆ្នាំនោះទេដែលប្រមូលទ្រព្យសម្បត្តិយកទៅដាក់រួមអីហ្នឹងមានគោក្របីអីហ្នឹង មានតែសម័យមុនហ្នឹងទេ ពីសម័យបីឆ្នាំនោះទេ ។

វណ្ណៈ៖ តែនៅនេះមានប្រជាជនថា បានប្រមូលដែលដូចថាមើលទៅសុន សេនគាត់មើលថា ប្រជាជនបែកឆ្វេងដូចថាទៅរកស៊ីមានលុយចាយខ្លះចឹងទៅ លែងចង់ទៅវៃជាមួយទាហានខាងរដ្ឋាភិបាលខាងក្នុងហើយ ដូច្នេះគាត់ត្រូវតែប្រមូលទ្រព្យសម្បត្តិដើម្បីឲ្យមានគំនិតមូលទៅមុនវិញ អាហ្នឹងគេនិយាយចឹងជាការពិតមែនឬមួយពូមិនបានដឹងទេ?

រីមៈ សម័យហ្នឹងបើនិយាយទៅវាពិតមែន តែគ្រាន់នៅក្នុងអង្គភាពនេះអត់មានទេ ។

វណ្ណៈ៖ បាទ ។

រីមៈ បើនៅពួកខ្ញុំខាងនេះអត់ទេ ។

វណ្ណៈ៖ បាទ ។

រីមៈ ដូចថានៅខាងចក្រីអីចឹងទៅខាងសំពៅលូនខាងហ្នឹងមានមែន ។

វណ្ណៈ៖ បាទ ។

រីមៈ ដូចថាអ្នកខ្លះហ្នឹងគេមានសមត្ថភាពគេរកស៊ីនេះនោះទៅគេមានគោមានរទេះអីចឹងទៅសម័យហ្នឹងគេយកពីខាងហ្នឹងមកដាក់រួម តាមអង្គភាពសម័យហ្នឹងមានមែន ។

វណ្ណៈ៖ ចឹងកាលនៅក្នុងសម័យខ្មែរក្រហមពូនៅខាងព្រំដែនយោធាអីចឹងពូដែលជួយប្រជាជនឬមួយជួយឲ្យចំណីអាហារឲ្យប្រជាជនអីដែរពូកាលហ្នឹង?

រីមៈ សម័យហ្នឹងមានឲ្យដែលពេលចុះទៅពីភ្នំដងរែកម្ដងៗចឹងទៅហ្នឹង ដល់ចឹងឲ្យសម្ភារដូចជាខោអាវសម្ភារផ្សេងៗដូចជាក្រមាដូចជាស្បែកជើង ។

វណ្ណៈ៖ ចឹងអ្នកដែលពូឲ្យហ្នឹងពូមានចាំឈ្មោះគេដែរ?

រីមៈ អូរមិនបានចាំទេ នៅក្នុងៗនោះនៅខាងខេត្តកំពង់ធំចឹងទៅ នៅខេត្តមណ្ឌលគិរីចឹងទៅពួកខ្ញុំចុះទៅដល់ហ្នឹងតើ មុនសញ្ញានៅខាងហ្នឹង ។

វណ្ណៈ៖ កាលពូនៅជាយោធាប្រចាំការនៅមណ្ឌលគិរីហ្នឹង តើមានឃើញកម្មាភិបាលខ្មែរក្រហមណាខ្លះចុះទៅប្រជុំចុះទៅអីហ្នឹង ទៅណែនាំយោបល់អីខ្លះទេពូ?

រីម៖ មានតែប្រធានកងពលហ្នឹង គាត់ជាអ្នកឃោសនាអប់រំប្រជាជនគឺប្រធានកងពលហ្នឹង ឥឡូវគាត់ពាក់លីបាត់ហើយ គាត់ពាក់លីយូរដែលហើយ ។

វណ្ណៈ៖ ពីណាគេទៅ?

រីម៖ ឈ្មោះ វឿន ដែលខ្ញុំថាហ្នឹង ។

វណ្ណៈ៖ ចឹងខាងមណ្ឌលគីរីទៅជា តា វឿនអីវិញ ខាងរតនៈគីរីមានតា ០៥តា សារឿនថាអី ពូមានស្គាល់ដែរ?

រីម៖ បាទ!ស្គាល់ ។

វណ្ណៈ៖ ចឹងតា សារឿនអីអត់មានមកគ្រប់គ្រងពូទេ?

រីម៖ បាទ ។

វណ្ណៈ៖ ចឹងតា កែវ ពកអីគាត់ទៅគ្រប់គ្រងខាងហ្នឹងដែលអត់ទេ?

រីម៖ សម័យហ្នឹងកាលឆ្នាំ៨២-៨៣ហ្នឹងឡើងមកមូលគ្នានៅភ្នំដងរែកហ្នឹង ដល់ចឹងគេទទួលតាមកងពលផ្សេងគ្នាទៅណាស់ ។

វណ្ណៈ៖ បាទ ។

រីម៖ ដោយឡែកនៅខាងហ្នឹង តា សុន សេនគាត់ក្តាប់រួមនៅខាងហ្នឹង ។

វណ្ណៈ៖ បាទ ។

រីម៖ ដូចជាតា ពកអីគាត់នៅខាងក្រោមហ្នឹងទៀត ដូចជាតា សារឿនអីហ្នឹងគាត់ក្រោមហ្នឹងមកទៀត មានកងពលធំកងពលតូចអីគេហ្នឹងចឹងទៅ តាមលំដាប់ថ្នាក់របស់គេ ។

វណ្ណៈ៖ បាទ!ចឹងមកដល់ឥឡូវហ្នឹងអ្នកស្រុកអ្នកភូមិហ្នឹងចាប់ផ្តើមមានវត្តមានសាលារៀនអីច្រើនចាប់ពីពេលណាមកដែរ មានផ្ទះសំបែងល្អៗអី?

រីម៖ មានផ្ទះសំបែងល្អៗមកគិតទៅវាចូលឆ្នាំ២០០០ដូចជាផ្ទះខ្ញុំចឹងចាប់ផ្តើមសង់តាំងពីឆ្នាំ២០០០មក ។

វណ្ណៈ៖ ចឹងចាប់តាំងពីឆ្នាំ២០០០មកបានមានផ្ទះល្អៗខ្លះ?

រីម៖ បាទ ។

វណ្ណៈ៖ ចឹងមានវត្តប៉ុន្មាននៅភូមិនេះ?

រីម៖ ភូមិនេះមានវត្តមួយ ។

វណ្ណៈ៖ ចឹងមួយភូមិមានវត្តមួយដែលអត់ពូតាមពូដឹងក្នុងមួយភូមិ?

វីមៈ អត់ទេ នៅក្នុងឃុំអូរដាវនេះមានតែវត្តពីរហ្នឹងនៅក្នុងឃុំអូរដាវអេ!មិនមែនវត្តពីរវត្តមានបីនោះ ។

វណ្ណៈ ចឹងមួយឃុំ?

វីមៈ បាទ!បើនៅខាងនេះមានតែភូមិអូរគគីរមួយទៅខាងនោះនៅក្នុងឃុំអូរដាវដែរ តែមានវត្តខាងកំពង់លៃខាងសំរោងនោះ ។

វណ្ណៈ បាទ ។

វីមៈ ហ្នឹងនៅក្នុងឃុំអូរដាវដែរ នៅក្នុងឃុំហ្នឹងមានវត្តបី ។

វណ្ណៈ បាទ ។

វីមៈ នៅភូមិខាងហ្នឹងវាដាច់ឆ្ងាយពីគេដល់ចឹងគេបង្កើតវត្ត កាលពីដើមភូមិសំរោងកំពង់លៃមកវត្តនេះដែរ ។

វណ្ណៈ បាទ ។

វីមៈ ដល់ពេលពិបាកធ្វើដំណើរពេក ចឹងទៅគេកកើតវត្តនៅនោះមួយទៅ ។

វណ្ណៈ បាទ ។

វីមៈ ខាងកំពង់លៃ ។

វណ្ណៈ ចឹងសម័យឥឡូវយើងមានវត្តមានសាសនាក្មេងប្រពៃណីមានពិធីរៀបការបុណ្យសពបុក៏បុណ្យពិធីអីផ្សេងៗអីចឹង ដោយឡែកជំនាន់ខ្មែរក្រហមអត់មានចឹង តើពូគិតថាយ៉ាងម៉េចដែលចិត្តរបស់ពូថាមួយណាល្អជាងមួយណា?

វីមៈ សើច...ដូចថាសម័យនេះគេអភិវឌ្ឍន៍ជឿនលឿនទៅ ចឹងថាសម័យនេះវាស្រួលជាងពីមុនឆ្ងាយណាស់ ។

វណ្ណៈ បាទ!ចឹងពូមានដឹងថាហេតុអីគោលការណ៍ខ្មែរក្រហមមិនឲ្យមានវត្តអីចឹង តើពូអាចដឹងពីគោលគំនិតរបស់ថ្នាក់លើខ្លះទេ?

វីមៈ គោលគំនិតថ្នាក់លើបានដឹងខ្លះៗដែលដូចថាគេចង់ធ្វើជាកុម្មុយនីស្តបើនិយាយទៅដូចថា ចង់ធ្វើតាមដូចចិន ។

វណ្ណៈ ចឹងចង់ធ្វើដូចកុម្មុយនីស្តចិន?

វីមៈ បាទ!ជំនាន់ហ្នឹងគេហៅបក្សកុម្មុយនីស្ត ជំនាន់បីឆ្នាំហ្នឹងគេហៅបក្សកុម្មុយនីស្ត ។

វណ្ណៈ ចឹងពូគិតមេដឹកនាំខ្មែរក្រហមមេដឹកនាំធំៗ ពូគិតថាដឹកនាំចឹងត្រឹមត្រូវឬមិនត្រឹមត្រូវទេ បើតាមទស្សនៈរបស់ពូផ្ទាល់?

រីមៈ តាមទស្សនៈរបស់ខ្ញុំហ្នឹងបើនិយាយថា ឲ្យវាត្រឹមត្រូវក៏ថាបានមិនត្រឹមត្រូវក៏ថាបានសម័យហ្នឹង ដូចថាអ្នកខ្លះវាខុសទៅជាត្រូវអ្នកត្រូវទៅជាខុស ចឹងហើយបានជាមានការកើតឡើងកាប់សម្លាប់គ្នា ។

វណ្ណៈ៖ ចឹងពូគិតថាប្រជាជនស្លាប់ជាងមួយលាននាក់ហ្នឹង ពូថាថ្នាក់ក្រោមជាអ្នកប្រព្រឹត្តិខុសឬក៏ថ្នាក់លើជាអ្នកប្រព្រឹត្តិខុសបញ្ហាទាំងអស់ហ្នឹង?

រីមៈ បញ្ហាទាំងអស់ហ្នឹងជួនកាលដូចថា វាមើលមិនឃើញអានេះដូចថាត្រីរស់នៅក្នុងទឹកល្អក់យើងមិនអាចមើលឃើញ ។

វណ្ណៈ៖ ចឹង?

រីមៈ ដល់ចឹងជួនកាលសម្លាប់ទៅគ្នាអត់មានកំហុសអីហ្នឹងយកគ្នាទៅសម្លាប់ទៅក៏មាន ។

វណ្ណៈ៖ បាទ ។

រីមៈ ជួនកាលសម្លាប់ទៅវាត្រូវពិតមែនក៏មាន ។

វណ្ណៈ៖ បាទ ។

រីមៈ តែគ្រាន់តែថា ការសម្លាប់នេះវាខុសការសម្លាប់គ្មានភស្តុតាងវាច្រើន ។

វណ្ណៈ៖ បាទ ។

រីមៈ ជាក់ស្តែងភស្តុតាងវាមានតិចណាស់ ។

វណ្ណៈ៖ បាទ ។

រីមៈ ការសម្លាប់សម័យហ្នឹង ។

វណ្ណៈ៖ ដោយសារប្រទេសយើងចូលទៅក្នុងអង្គការសហប្រជាជាតិហើយកាលសម្លាប់ប្រជាជននិងពូមើលឃើញការសម្លាប់មិនដឹងជាយ៉ាងម៉េចដែរ សូម្បីតែអ្នកដឹកនាំកម្មាភិបាលធំខ្លួនឯងហ្នឹងក៏យកទៅសម្លាប់ហើយមិនមែនសម្លាប់តែពូជាអ្នកខុសទេ ឪពុកនិងជាអ្នកខុសតែកូននិងប្រពន្ធនោះអត់មានបានទៅចូលរួមជាមួយដូចជាកូនងែតប៉ុននេះយកទៅសម្លាប់ចោលអីដែរចឹង ពូគិតថាចឹងជាការត្រឹមត្រូវដែលឬមួយមិនត្រឹមត្រូវទេ?

រីមៈ អាហ្នឹងធ្វើចឹងវាមិនត្រឹមត្រូវទេ គ្នាកូនក្មេងកូនងែតនៅក្នុងអង្រឹងគ្នាគ្មានដឹងអីទេ យកគ្នាទៅសម្លាប់ទៅអាហ្នឹង អាហ្នឹងគឺជាការខុសទាំងស្រុងតែម្តង ។

វណ្ណៈ៖ ចឹងពូគិតថាជាការអស់សង្ឃឹមដែលអត់បើសិនជាខ្លួនបានបំរើឲ្យខ្មែរក្រហមហើយ ប៉ុន្តែខ្មែរក្រហមហ្នឹងយកពូទៅសម្លាប់ទៀតនេះ អាហ្នឹងពីគិតយ៉ាងម៉េចវិញ?

រីមៈ អាហ្នឹងយើងមានការអាក់អន់ចិត្តហើយ ។

វណ្ណៈ៖ ចឹងពូគិតថាអ្នកដឹកនាំហ្នឹងមានគោលបំណងណាមួយពីណាពីណើមកដើម្បីឲ្យខ្មែរអស់ពីទឹកដីខ្មែរ ឬក៏យ៉ាងម៉េចដែរ បើតាមពូគិតលេង ព្រោះការសម្លាប់វាវិញដុំពីថ្នាក់ក្រោមមុនដំបូង សម្លាប់ពួកនាយទន់ ពួកមន្ត្រីរាជការលន់ នល់ យើងមើលឃើញពួកហ្នឹងមែន ជិះដាន់អី មែនដល់ពេលសម្លាប់ពួកហ្នឹងអស់ហើយ ហេតុអីក៏ចាប់ផ្ដើមសម្លាប់គ្នាឯងទៀត?

រីមៈ អាហ្នឹងបើគិតទៅអ្នកខ្លះមានគំនុំគ្នាចឹងទៅ ។

វណ្ណៈ៖ ចឹង?

រីមៈ បាទ!ខ្លះមានគំនុំចឹងទៅ ដូចជាពាក្យមួយថាគំនុំតពូជ ។

វណ្ណៈ៖ ចឹងពីគិតថាសព្វថ្ងៃហ្នឹងមានតុលាការកាត់ទោសអីចឹងពីគិតថាជាការត្រឹមត្រូវឬមួយជាការ មិនត្រឹមត្រូវទេ?

រីមៈ តុលាការកាត់ទោសហ្នឹង គេកាត់ទោសជួនកាលសម័យនេះបើគិតទៅបើគិតវាឲ្យដល់ទៅតុលាការខ្លះក៏កាត់ត្រឹមត្រូវខ្លះក៏មិនត្រឹមត្រូវ ។

វណ្ណៈ៖ តែតុលាការរាល់ថ្ងៃហ្នឹងជាតុលាការអន្តរជាតិនិងតុលាការខ្មែរធ្វើចឹងត្រឹមត្រូវឬមិនត្រឹមត្រូវទេ?

រីមៈ សព្វថ្ងៃបើគេធ្វើឲ្យចំចំណុចទៅវាត្រឹមត្រូវខ្លះធ្វើមិនត្រឹមត្រូវហ្នឹង ខ្លះធ្វើទៅអាងមានលុយកាក់ចឹងទៅក៏ខុសពីសំណុំបែបបទដែរ អ្នកប្រព្រឹត្តិចឹងក៏មាន ។

វណ្ណៈ៖ បាទ!តែនេះយើងសំដៅលើតុលាការខ្មែរក្រហមមួយទេ សព្វថ្ងៃមានតាអៀង សារី តានួន ជា តា ខៀវ សំផន តា ឌុចគេកាត់ទោសហើយចឹង ។

រីមៈ បាទ ។

វណ្ណៈ៖ ហើយមានប្រពន្ធអៀង សារី សព្វថ្ងៃពួកគាត់កំពង់តែជាប់ឃុំឃាំងនៅតុលាការនិងរងចាំការការកាត់សេចក្ដីនៅប៉ុន្មានខែខាងមុខនេះ ចឹងពួកគាត់ជាប់នៅហ្នឹងត្រូវការកាត់ទោសពួកគាត់ហ្នឹង ពូគិតថាជាការត្រឹមត្រូវឬមិនត្រឹមត្រូវទេ អាចឲ្យមានបញ្ហាអីកើតឡើង?

រីមៈ អានេះបើគិតទៅខាងផ្នែកនយោបាយ ដូចថាខ្ញុំវាមិនយល់ទេបញ្ហានិងស្រេចតែលើគេ ។

វណ្ណៈ៖ បាទ!ចឹងពីគិតថាគាត់ទោសទៅវាមានសារៈសំខាន់អីបើមិនកាត់ទោសវាមានសារៈសំខាន់អីដែរ?

រីមៈ អានេះបើនិយាយទៅវាឆាកនយោបាយអ្នកដឹកនាំមួយៗ គេកាត់សាចុះសាឡើងបើនិយាយទៅកាត់ដឹងប៉ុន្មានដងហើយតែមិនចេះឃើញស្រេច ។

វណ្ណៈ៖ តែមិនទាន់បានកាត់ណា តា ឌុចទើបចាប់ផ្ដើមកាត់?

រីមៈ បាទ ។

វណ្ណៈ ហើយប៉ុន្មានថ្ងៃខាងមុខនេះគេប្រកាសសាលក្រមថាត្រូវជាប់ប៉ុន្មានឆ្នាំៗហ្នឹងណាស់?

រីមៈ បាទ ។

វណ្ណៈ ប៉ុន្តែតា អៀង សារីតា នួន ជាត្រូវគេកាត់ប៉ុន្មានខែខាងមុខទៀតនេះ គេកាត់ទាំងអស់រួមគ្នាតែម្ដង អាហ្នឹងជាគំនិតរបស់ពូទេ ពូថាល្អក៏ល្អពូថាមិនល្អក៏មិនល្អ តែបើសិនជាពូថាមិនត្រូវកាត់ទេ ឧបមាថាចឹង?

រីមៈ បាទ ។

វណ្ណៈ អូ!មិនបាច់កាត់គាត់ទេ គាត់ចាស់ហើយបើសិនជាពូគិតចឹងពូមានគំនិតចឹង បើពូគិតទៅថ្ងៃក្រោយទៀតបើសិនជាមានអ្នកធ្វើចឹងទៀត ដល់ពេលមានអ្នកប្រព្រឹត្តិចឹងទៀត ចឹងបើសិនជាគ្មានតុលាការកាត់ទោសទេ តើប្រទេសមួយទាំងមូលនេះស្រុកខ្មែរនេះ ពូជឿថាមានការកាប់សម្លាប់គ្នាសេរីទៀតដែលអត់ បើសិនជាគ្មានតុលាការទេ បើពូគិតថាគាត់ចាស់អស់ហើយ មិនបាច់កាត់ទោសអីទេ អាហ្នឹងយើងនិយាយលេង តែអ្នកក្រោយទៀតគេឡើងគេថាអ្នកដឹកនាំមុនសម្លាប់មនុស្សអស់រាប់លានគេមិនថាអីផង អ្នកមកក្រោយឡើងមកកាប់សម្លាប់ប្រជាជនចោលទៀតទៅមានស្អីឲ្យតែទឹសមុខមាត់ ចឹងពូគិតថាការកាត់ទោសហ្នឹងជាសារៈសំខាន់ក្នុងការទប់ស្កាត់ឬក៏វាគ្មានសារៈសំខាន់ទេ តាមយោបល់ពូ?

រីមៈ តាមយោបល់ខ្ញុំការកាត់ទោសចឹងជាការត្រឹមត្រូវល្អហើយ ។

វណ្ណៈ ចឹង?

រីមៈ ព្រោះថាច្បាប់គេតែងតែមានការកាត់ទោសចឹងហើយ មនុស្សតែមានខុសចឹងទៅត្រូវតែឡើងតុលាការហ្នឹងហើយ គេត្រូវកាត់ទោសចឹងហើយ ។

វណ្ណៈ ចឹងបើសិនជាអត់មានតុលាការអ្នកដឹកនាំក្រោយអត់ខ្លាចទេ?

រីមៈ បាទ ។

វណ្ណៈ ឡើងមកបានអំណាចហើយអញហើយ?

រីមៈ បាទ ។

វណ្ណៈ ចឹងបើមានតុលាការអាចទប់ស្កាត់ម្យ៉ាងដែរ?

រីមៈ បាទ ។

វណ្ណៈ ទោះបីជាយើងមានចំណាស់ប៉ុន្មានក៏ដោយតែយើងធ្លាក់ពីអំណាចទៅយើងត្រូវគេកាត់ទោសហើយ?

វីមៈ បាទ ។

វណ្ណៈ បើយើងធ្វើឲ្យប្រជាជនស្លាប់ច្រើន?

វីមៈ បាទ ។

វណ្ណៈ តែបើអ្នកដឹកនាំមិនបានធ្វើឲ្យប្រជាជនស្លាប់ច្រើនទេវាក៏មិនអីដែរ?

វីមៈ បាទ ។

វណ្ណៈ គឺយើងចុះដោយស្រួលចឹងទៅ អត់មានបញ្ហាអីទេ?

វីមៈ បាទ ។

វណ្ណៈ ចឹងពូបើសិនមកដល់សព្វថ្ងៃនេះប្រជាជនរស់នៅធ្វើស្រែចំការមានការរីកចំរើនដែលឬក៏យ៉ាងម៉េច?

វីមៈ សព្វថ្ងៃនេះក្នុងការបន្កបង្កើនផលស្រែចំការអីអាហ្នឹងវាអំណោយផលទៅតាមធម្មជាតិដែរ ធម្មជាតិវាអំណោយផលឲ្យមកការបង្កើតកសិផលហ្នឹងក៏បានល្អបានរីកចំរើនទៅ ។

វណ្ណៈ បាទ ។

វីមៈ បើធាតុអាកាសវាមិនអំណោយផលទេ ដូចជាទឹកភ្លៀងអីចឹងមកក៏វាខាតបង់ចឹងទៅ ដូចកាលឆ្នាំទៅចឹង វាមិនអំណោយផលចឹងទៅ យើងដាំកសិផលដូចជាដំឡូងពោតចឹងទៅខ្លះដាំទៅបានពាក់កណ្ដាលមកវិញក៏មាន ។

វណ្ណៈ បាទ!ចឹងភាគច្រើនប្រជាជននៅស្រុកកំរៀងហ្នឹងគេដាំអីច្រើនជាងគេ គេប្រកបមុខរបរអី?

វីមៈ នៅនេះគេប្រកបមុខរបរដាំដំឡូងពោត សណ្ដែក ។

វណ្ណៈ បាទ ។

វីមៈ សណ្ដែកបាយនិងសណ្ដែកសៀង ។

វណ្ណៈ បាទ!ចឹងពូរាល់ថ្ងៃធ្វើស្រែចំការឬមួយយ៉ាងម៉េច?

វីមៈ ធ្វើស្រែចំការ ។

វណ្ណៈ ចឹងអត់មានធ្វើអីទេ?

វីមៈ អត់មានធ្វើអីទេឥឡូវ កាលហ្នឹងខ្ញុំឈប់ធ្វើជាទាហានតាំងពីយូរហើយ ។

វណ្ណៈ ចឹងពូឈប់មុនសមាហរណ៍កម្មឬមួយឈប់ក្រោយទេ?

វីមៈ ឈប់ក្រោយ ។

វណ្ណៈ ចឹងពូនៅបានប្រាក់បៀវត្សរ៍សន្តមកិច្ចទេ?

រីមៈ សម័យហ្នឹងខ្ញុំនៅជាទាហានដែរ ខាងរាជរដ្ឋាភិបាលខបត្តមប្រាក់ខែដែរ ត្រង់ថាជួនកាលបីបួនខែចឹងទៅឃើញបានពីរបីម៉ឺនខ្មែរមកចឹងមក ។

វណ្ណៈ យ៉ាងម៉េចចឹង?

រីមៈ សម័យហ្នឹងមិនដឹងជាគេរៀបចំមិនដឹងជាយ៉ាងម៉េច ខ្ញុំមិនដឹងដែលដល់ចឹងដូចថាខាងលើៗបន្តបន្ទាប់មកពីខាងរាជរដ្ឋាភិបាលគេឲ្យមកហើយ តែវាស៊ីនៅខាងក្រោមៗនេះ ។

វណ្ណៈ ចឹងឥឡូវពូមិនទាន់រីត្រែតទេ?

រីមៈ ខ្ញុំមិនទាន់រីត្រែតទេ តែខ្ញុំឈប់ធ្វើយូរដែលហើយតាំងពីសមាហរណ៍កម្មហើយពីរឆ្នាំបីឆ្នាំហើយ ។

វណ្ណៈ បាទ ។

រីមៈ ឈ្មោះ របស់ខ្ញុំនិងគេស៊ីទេ គេយកឈ្មោះខ្ញុំទៅលក់ឲ្យអ្នកផ្សេង ។

វណ្ណៈ បាទ ។

រីមៈ ឈ្មោះខ្ញុំនៅមានដែលតែគេដាក់ឲ្យអ្នកផ្សេងគេយកឈ្មោះខ្ញុំ ។

វណ្ណៈ បាទ!ចឹងឥឡូវពូប្រកបមុខរបរធ្វើស្រែចំការវិញទៅ?

រីមៈ បាទ!ដូចថាវាធុញនិងសង្រ្គាមហើយ វាឆ្អែតហើយបើគិតទៅតាំងពីខ្ញុំធំដឹងក្តីរៀនតិចតួចចឹងដល់ចឹងវាសង្រ្គាមពីរជំនាន់ដល់ចឹងវាធុញទ្រាន់ក្នុងការច្បាំងអី ។

វណ្ណៈ ចឹងពូមានជំជឿថាថ្ងៃក្រោយខ្មែរនិងខ្មែរមានបញ្ហាវៃគ្នាទៀតឬមួយមិនមានទេ តាមពូគិតលេង?

រីមៈ តាមខ្ញុំគិតលេងដូចជាគ្មានទេ ។

វណ្ណៈ ចឹងមិនអាចមានទេ?

រីមៈ មិនអាចមានទៀតទេ ។

វណ្ណៈ ព្រោះអីអ្នកតស៊ូមុនគេធ្លាប់ភ្លក់រស់ជាតិអស់ហើយមិនអាចឃោសនាអ្នកណាទៀតទេ?

រីមៈ បាទ ។

វណ្ណៈ ចង់អ្នកធំណាទៅឃោសនាអីក៏ដោយ?

រីមៈ ឃោសនាអីទៀតមិនទេ ។

វណ្ណៈ ចឹងបើសម្តេចប្រកាសថា កូនចៅចូលព្រៃម៉ាគីម្តងទៀតពូទៅទេ?

រីមៈ ទេ មិនទៅទេសម្តេចឪទៅខ្លួនឯងទៅសើច... ។

វណ្ណៈ លែងទៅហើយ?

រីមៈ ចំណាស់នេះហើយ អើបើថាជនជាតិបរទេសដូចជាថៃដូចជាអី បើមកឈ្លានពានខ្មែរនិង ត្រូវកាន់អាវុធបន្តទៀតហើយ ។

វណ្ណៈ មានទឹកចិត្តទៅទៀត?

រីមៈ បាទ!មានទឹកចិត្តទៅទៀត ព្រោះថាគេមកឈ្លានពានយើង គេមកយកទឹកដីយើងហើយ ។

វណ្ណៈ គេមកយកដីស្រែយើងហើយយើងនៅអីទៀត?

រីមៈ បាទ ។

វណ្ណៈ ចឹងបើវៃជាមួយបរទេសវៃទៀត?

រីមៈ បាទ ។

វណ្ណៈ បើខ្មែរឈប់វៃតែម្ដង?

រីមៈ បាទ!បើខ្មែរវៃខ្មែរឈប់វៃ បើវៃឲ្យតែកើតសង្គ្រាមហើយវាគ្មានចំណេញទេ វាមានតែ ខាតបង់ទាំងសងខាង ។

វណ្ណៈ ចឹងគ្នាឯងលែងវៃហើយ?

រីមៈ បាទ ។

វណ្ណៈ តែបើជាមួយបទេសវៃទៀត?

រីមៈ បាទ!បើជាមួយបរទេសមកវៃទៀត ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់អីសួរពូហើយ ចង់ជំរាបពូថាពត៌មានរបស់ខ្ញុំដែលសម្ភាសជាមួយពូហ្នឹងតើ ពូអនុញ្ញាតឲ្យសរសេរជាសៀវភៅឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានពូបានទេ?

រីមៈ បានតើ ។

វណ្ណៈ ចឹងអត់អីទេ?

រីមៈ មានអី ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយ ។

រីមៈ បាទ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូដែលបានចំណាយពេលវេលាឲ្យពួកខ្ញុំបានសម្ភាស ។

រីមៈ បាទ ។

វណ្ណៈ ចឹងអរគុណពូច្រើន ។

រីមៈ បាទ ។

**ចប់**